បញ្ជ្រុះក្តីសង្ស័យពីបេះដូងហើយផ្ទុកផ្ទាយពន្លឺនៃសេចក្តីស្រឡាញ់

កូនក្មេងកម្ពុជាមួយក្រុមបានត្រឡប់ទៅវិញ ដើម្បីទស្សនាខេត្តយូណានម្តងទៀត។ ពួកគេបានប្រើដៃទាំងពីរជ្រលក់ក្នុងថ្នាំលាបចម្រុះពណ៌ និងដាក់ដៃនៅលើក្រដាសគំនូរដោយញញឹម ដើម្បីបន្សល់ទុកស្នាមដៃរបស់ពួកគេនៅលើផ្ទាំងគំនូរសម្រាប់កម្មវិធីដំណើរនៃការដឹងគុណនៃគម្រោង "ដំណើរនៃក្តីស្រឡាញ់" ចិន-កម្ពុជា ។ ថ្មីៗនេះ ដំណើរទស្សនកិច្ចទៅកាន់ខេត្តយូណានសម្រាប់កុមារដែលមានជំងឺបេះដូងពីកំណើតដែលបានជាសះស្បើយដោយសារគម្រោង "ដំណើរនៃក្តីស្រឡាញ់" កម្ពុជា -ចិន ឆ្នាំ ២០២៥ ត្រូវបានចាប់ផ្តើមនៅមន្ទីរពេទ្យជំងឺបេះដូង និងសរសៃឈាម ហ្ស្វូវ៉ី ខេត្តយូណាន។ ព្រឹត្តិការណ៍នេះបានអញ្ជើញកុមារដែលជាសះស្បើយពីជំងឺបេះដូងពីកំណើត ឪពុកម្តាយ តំណាងអ្នកស្ម័គ្រចិត្ត និងថ្នាក់ដឹកនាំគម្រោងសំខាន់ៗរបស់កម្ពុជាមកកាន់ខេត្តយូណាន។ តាមរយៈការចុះទៅទស្សនានៅតាមកន្លែង និងការផ្លាស់ប្តូរនេះ ហើយបន្តបន្ថែមខ្លឹមសាររឿងរ៉ាវមិត្តភាពរបស់ពួកគេជាមួយខេត្តយូណាន។

ត្រឡប់ទៅខេត្តយូណានវិញ ត្រឡប់ទៅចំណុចចាប់ផ្តើមនៃការកើតឡើងវិញ

កន្លែងឈប់ដំបូងនៃសកម្មភាពនេះ កុមារវិលត្រឡប់ទៅកាន់មន្ទីរពេទ្យជំងឺបេះដូង និងសរសៃឈាម ហ្ស្វូវ៉ី ខេត្តយូណាន។ នេះគឺជាចំណុចចាប់ផ្តើមសម្រាប់ជីវិតថ្មីរបស់ពួកគេ។

ឌូ តុង អាយុ ១៩ ឆ្នាំ បានធំឡើងពីក្មេងប្រុសតូចស្គមស្គាំងដែលមានបបូរមាត់ពណ៌ស្វាយ ដង្ហក់បន្ទាប់ពីដើរបានតែប៉ុន្មានជំហានប៉ុណ្ណោះ ក្លាយទៅជានិស្សិតមហាវិទ្យាល័យដ៏ស្វាហាប់ម្នាក់។ គាត់បានប្រាប់អ្នកកាសែតថា ក្នុងដំណើរកម្សាន្តនេះ ចិត្តខ្ញុំពោរពេញដោយការដឹងគុណយ៉ាងស្មោះស្ម័ត្រ ខ្ញុំសូមថ្លែងអំណរគុណដល់មន្ទីរពេទ្យជំងឺបេះដូងនិងសរសៃឈាម ហ្ស្វូវ៉ី ខេត្តយូណាន និងសូមថ្លែងអំណរគុណដល់ក្រុមគ្រូពេទ្យ ចំពោះការព្យាបាល ការសម្របសម្រួល និងការលើកទឹកចិត្តរបស់ពួកគេ។

ភាគច្រើនកុមារទាំងនេះមកពីតំបន់ជនបទនៃប្រទេសកម្ពុជា សម្រាប់ពួកគេ ដំណើរកម្សាន្តលើកដំបូងរបស់ពួកគេទៅកាន់ខេត្តយូណានគឺសម្រាប់ការវះកាត់។ ដោយសារតែភាពមិនស៊ាំ និងមិនស្គាល់ ពួកគេបានចូលទៅក្នុងមន្ទីរពេទ្យដោយការភ័យខ្លាចនិងការព្រួយបារម្ភ។ លោកស្រី យ៉ាង លីហួរ នាយកមជ្ឈមណ្ឌលស្រាវជ្រាវសុខភាព និងអាកប្បកិរិយាយូនឌី(YUNDI) គុនមីង បាននិយាយថា យើងបានរៀបចំ "ដំណើរនៃការដឹងគុណ" នេះ ដើម្បីនាំកុមារត្រឡប់មកខេត្តយូណានវិញ ទៅកាន់បន្ទប់ជំងឺដែលពួកគេធ្លាប់ស្នាក់នៅ ដើម្បីជួបគ្រូពេទ្យដែលបានព្យាបាលពួកគេ ហើយបន្ទាប់មកនាំពួកគទៅទស្សនាទេសភាពតាមដងផ្លូវ និងទីផ្សារ ដើម្បីទស្សនាមើលខេត្តយូណានពិតប្រាកដហើយទទួលបានបទពិសោធន៍បរិយាកាសរស់រវើក និងភាពកក់ក្តៅរបស់ប្រជាជនស្នាក់នៅក្នុងតំបន់។

ដំណើរនេះបានលាតសន្ធឹងពីមន្ទីរពេទ្យរហូតដល់ដងផ្លូវ និងទីផ្សារតូចចង្អៀតនៃទីក្រុងគុនមីង ព្រមទាំងសាលរំលឹកខួបនៃជ័យជម្នះសង្គ្រាមប្រឆាំងនឹងការឈ្លានពានរបស់ជប៉ុនក្លោងទ្វារជ៥ម៉ាពីជី ផ្សារបន្ទែតាក្ងានជ៥ស៊ីន និងផ្សារផ្កាទូរ៉ណាន... កុមារទាំងនេះដើរចេញពីគ្រែមន្ទីរពេទ្យចូលទៅក្នុងពិភពលោកដ៏ធំទូលាយ ហើយបានទទួលអារម្មណ៍ពីភាពកក់ក្តៅនៃទីក្រុងដោយស្មោះអស់ពីចិត្ត។ កុមារម្នាក់ឈ្មោះ ប៉េង សេឡា បាននិយាយថា ខ្ញុំនឹងខិតខំសិក្សានៅថ្ងៃអនាគត ហើយខិតខំព្យាយាមមកបន្តការសិក្សានៅប្រទេសចិន។ ដំណើរកម្សាន្តនេះបានកំណត់ប្រៃការយល់ដឹងរបស់កុមារ និងក្រុមគ្រួសាររបស់ពួកគេអំពីប្រទេសចិនឡើងវិញ។

ម្តាយកុមារ ម៉ូ ចាន់តា បានរំលឹកឡើងវិញនូវការបារម្ភ និងភាពអស់សង្ឃឹមដែលលោកស្រីមានកាលពីប្រាំមួយឆ្នាំមុន នៅពេលដែលគាត់បាននាំកូនស្រីមកកាន់ទីក្រុងគុនមីងដើម្បីវះកាត់។ លោកស្រីបាននិយាយថា គ្រូពេទ្យចិនបានពន្យល់ដោយអត់ធ្មត់ និងហ្មត់ចត់អំពីរឿងរ៉ាវនានាដល់គាត់ ធ្វើឱ្យគាត់មានអារម្មណ៍ទុកចិត្ត។ លើកនេះលោកស្រីមកទីក្រុងគុនមីងម្តងទៀត ពិតជាពោរពេញដោយសេចក្តីរីករាយ។ លោកស្រីបានប្រាប់អ្នកកាសែតថា ខ្ញុំនឹងប្រាប់មិត្តជុំវិញខ្លួនខ្ញុំអំពីបទពិសោធន៍របស់ខ្ញុំ និងកូនរបស់ខ្ញុំនៅខេត្តយូណាន។ ពីម្តាយដែលអស់សង្ឃឹម ទៅជាអ្នកនាំសារនៃការដឹងគុណ បទពិសោធន៍របស់លោកស្រីគឺជាសក្តីភាពនៃការព្យាបាលអារម្មណ៍យ៉ាងជ្រាលជ្រៅ ដែលនាំមកដោយគម្រោង "ដំណើរនៃក្តីស្រឡាញ់"។

ការបញ្ជូនតន្លង់ដែន សាបព្រួសគ្រាប់ពូជនៃសេចក្តីស្រឡាញ់

គម្រោង "ដំណើរនៃក្តីស្រឡាញ់" មិនត្រឹមតែព្យាបាលបេះដូងរបស់កុមារប៉ុណ្ណោះទេ ថែមទាំងបានដាំគ្រាប់ពូជនៃសេចក្តីស្រឡាញ់នៅក្នុងចិត្តរបស់ពួកគេ ដែលជំរុញឱ្យសេចក្តីស្រឡាញ់ត្រូវបានបន្តតាមរយៈការបញ្ជូនបន្ត។

នៅក្នុងភូមិបន្ទាយស្រី ស្រុកបន្ទាយស្រី ខេត្តសៀមរាប ប្រទេសកម្ពុជា ចម្ប៉ា ហារ៉ា អាយុ ១៧ ឆ្នាំ ជិះកង់របស់នាងឆ្លងកាត់សួនច្បារ សក់វែងរបស់នាងបក់ហោកតាមខ្យល់ ស្នាមញញឹមរបស់នាងភ្លឺចែងចាំង។ តើអ្នកណានឹងគិតថាកាលពីប៉ុន្មានឆ្នាំមុន នាងជាកុមារដែលមានជំងឺបេះដូងពីកំណើត ពិបាកដកដង្ហើមសូម្បីតែពេលដើរក៏ដោយ នៅអាយុប្រាំបួនឆ្នាំ គម្រោង "ដំណើរនៃក្តីស្រឡាញ់" កម្ពុជា -ចិនបាននាំមកឱ្យនាងនូវចំណុចរបត់មួយ។ បន្ទាប់ពីការវះកាត់ដោយជោគជ័យ នាងបាននិយាយថា វេជ្ជបណ្ឌិតចិនបានជួយសង្គ្រោះខ្ញុំ ហើយខ្ញុំចង់បន្តសេចក្តីស្រឡាញ់នេះដល់មនុស្សផ្សេងទៀត។ ឥឡូវនេះនាងធ្វើការស្ម័គ្រចិត្តរៀងរាល់ចុងសប្តាហ៍នៅមណ្ឌលសុខភាពស្រុកបន្ទាយស្រី ដោយណែនាំផ្លូវសម្រាប់អ្នកជំងឺមកព្យាបាល។

ការផ្លាស់ប្តូរនេះមិនមែនជាករណីដាច់ដោយឡែកនោះទេ។ លោក លូ ជ៉ាង ជំនួយការប្រធាន និងជានាយកការិយាល័យកិច្ចការបក្ស និងរដ្ឋបាលទូទៅនៃមន្ទីរពេទ្យជំងឺបេះដូងនិងសរសៃឈាម ហ្ស្វូវ៉ី ខេត្តយូណាន បានចែករំលែករឿងមួយថា មានអ្នកជំងឺក្មេងស្រីតូចជនជាតិខ្មែរម្នាក់។ ពេលយើងសួរនាងថា នាងចង់ចូលធ្វើការអ្វីនៅពេលនាងធំឡើង នាងបានឆ្លើយភ្លាមៗថានាងចង់ក្លាយជាគ្រូពេទ្យ ដើម្បីអាចជួយមនុស្សបានកាន់តែច្រើន។

ការបញ្ជូនតគ្នានៃសេចក្តីស្រឡាញ់ក៏ត្រូវបានបង្ហាញចំពោះអ្នកស្ម័គ្រចិត្តផងដែរ។ អ្នកស្រី ឆែ ធីដា អាយុ ៣២ ឆ្នាំ ជាបុគ្គលិកនៃមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ បានបម្រើគម្រោង "ដំណើរនៃក្តីស្រឡាញ់" ដោយឥតគិតថ្លៃអស់រយៈពេលប្រាំបីឆ្នាំមកហើយ។ អ្នកស្រីបាននិយាយថា រាល់ពេលដែលខ្ញុំឃើញកុមារត្រឡប់មកផ្ទះវិញបន្ទាប់ពីការវះកាត់ដោយជោគជ័យ ខ្ញុំមានអារម្មណ៍រីករាយជាខ្លាំង។ ជាងនេះទៅទៀត មានអ្នកស្ម័គ្រចិត្តជាង ៣០ នាក់ដូចអ្នកស្រី បានតស៊ូចាប់តាំងពីគម្រោងនេះចាប់ផ្តើមរហូតមកដល់បច្ចុប្បន្ន។

ចំពោះលោក ណម សត្យារ៉ូ វេជ្ជបណ្ឌិតឯកទេសជំងឺបេះដូងនៅមន្ទីរពេទ្យព្រះកេតុមាលា ការបញ្ជូនតនេះត្រូវបានបង្ហាញឱ្យឃើញពីការប្រកាន់ខ្ជាប់ខាងវិជ្ជាជីវៈ។ លោកតែងតែបើករថយន្តរាប់រយគីឡូម៉ែត្រ ដើម្បីពិនិត្យសុខភាពឡើងវិញឱ្យកុមារដែលបានទទួលការវះកាត់ ព្រមទាំងទាក់ទងជាមួយអ្នកជំនាញនៅមន្ទីរពេទ្យជំងឺបេះដូង និងសរសៃឈាម ហ្ស្វូវ៉ី ខេត្តយូណានឱ្យទាន់ពេលវេលា ដែលបានក្លាយជា "ស្ពាន" តភ្ជាប់ក្រុមគ្រូពេទ្យរវាងប្រទេសទាំងពីរ។ ដោយធ្លាប់បានបន្តការសិក្សានៅប្រទេសចិនអស់រយៈពេលបួនឆ្នាំ ភាសាចិនជ៥ស្ទាត់ជ៥នាញរបស់លោកធ្វើឱ្យលោកក្លាយជាដៃគូដែលអាចទុកចិត្តបាននៅក្នុងក្រសែភ្នែករបស់គ្រូពេទ្យចិនផងដែរ។

ការផ្លាស់ប្តូរពីអ្នកទទួលជំនួយទៅអ្នកជួយគឺជាការបញ្ជូនបន្តនៃជីវិត និងសេចក្តីស្រឡាញ់ដែលបង្កើតឡើងដោយគម្រោង "ដំណើរនៃក្តីស្រឡាញ់" ហើយធ្វើឱ្យសុច្ឆន្ទៈលើសពីព្រំដែនជាតិ និងបន្តរីកចម្រើនឥតឈប់ឈរ។

អំណានបន្ថែម÷

គម្រោង "ដំណើរនៃក្តីស្រឡាញ់" កម្ពុជា-ចិន គឺជាគម្រោងសុខុមាលភាពសាធារណៈដ៏សំខាន់មួយ ក្នុងវិស័យសហប្រតិបត្តិការសុខភាពរវាងចិន និងកម្ពុជា ដែលមានគោលបំណងព្យាបាលកុមារកម្ពុជាដែលមានជំងឺបេះដូងពីកំណើត។ គម្រោងនេះ ត្រូវបានផ្តួចផ្តើមឡើងនៅឆ្នាំ ២០១៨ និងដឹកនាំដោយមន្ទីរពេទ្យជំងឺបេះដូង និងសរសៃឈាម ហ្ស្វូវ៉ី ខេត្តយូណាន នៃប្រទេសចិន គម្រោងមិនត្រឹមតែផ្តល់ការព្យាបាលវះកាត់ដោយឥតគិតថ្លៃសម្រាប់កុមារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខិតខំកែលម្អវេជ្ជសាស្ត្រក្នុងតំបន់ដោយបន្សល់ទុកនូវ "ក្រុមសុខាភិបាលមួយដែលមិនចាកចេញ"។

គិតមកដល់បច្ចុប្បន្នមន្ទីរពេទ្យនេះបានរួមគ្នាពិនិត្យកុមារកម្ពុជាជាង ៨ ម៉ឺននាក់ និងផ្តល់ការព្យាបាលដោយឥតគិតថ្លៃដល់កុមារជាង ១២០ នាក់ដែលមានជំងឺបេះដូងពីកំណើត។

តាមស្ថិតិ មន្ទីរពេទ្យជំងឺបេះដូង និងសរសៃឈាម ហ្ស្វូវ៉ី ខេត្តយូណាន បានបង្កើតកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាច្រើននៅប្រទេសជាច្រើនដូចជាប្រទេសឡាវ អ៊ូសបេគីស្ថាន និងតង់ហ្សានីជាដើម។ គេបានបញ្ជូនក្រុមគ្រូពេទ្យសរុបចំនួន ៣២ ក្រុមទៅក្រៅប្រទេស ដោយសហការគ្នាក្នុងការត្រួតពិនិត្យកុមារជាង ១១ ម៉ឺននាក់ និងផ្តល់ការព្យាបាលដោយឥតគិតថ្លៃដល់កុមារចំនួន ១៥៥ នាក់ដែលមានជំងឺបេះដូងពីកំណើត។ មិនតែប៉ុណ្ណោះទេ មន្ទីរពេទ្យបានទទួលបុគ្គលិកពេទ្យចំនួន ៣២ នាក់មកពី ១០ ប្រទេសសម្រាប់ការបណ្តុះបណ្តាលបន្ថែម៖

ដោយ ÷ កសិ្យាណ និង ម៉ាង ជ៉ីងចុង

អ្នកនិពន្ធភាសាចិន ៖ RAN XIULAN អ្នកនិពន្ធភាសាខ្មែរ ៖ LI ZHA SHEN YAN រចនារូបភាព ៖ SUN YONGGANG